# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*ព្រោះធម្មតាតែបាត់មនុស្សមួយៗ... គឺគេនិយាយហើយក្នុងមន្ទីរអង្គរក្សហ្នឹងបាត់*
*អ៊ីចឹងគេប្រាប់ថាគាត់ក្បត់ហើយ បានគេចាប់បាត់ហើយ។*[1]

- សាក្សី ស វិ

## I. ទិដ្ឋភាពទូទៅ

នៅក្នុងសប្តាហ៍ទី១នៃកិច្ចដំណើរការនីតិវិធីក្នុងឆ្នាំ២០១៣នេះ អង្គជំនុំជម្រះតុលាការជំបូង បានស្តាប់សក្ខីកម្មសាក្សី៣រូប លោក ស វិ លោក អ៊ុង រ៉ែន និង លោក ឆោម សែ។ សាក្សីទាំង៣ ជាអតីតទាហានខ្មែរក្រហម ហើយម្នាក់ៗបានពិភាក្សាលើបទពិសោធន៍របស់ខ្លួន នៅមុននិងក្នុងកំឡុងពេលខ្មែរក្រហមបានវាយលុកចូលភ្នំពេញក្នុង ខែ មេសា ឆ្នាំ ១៩៧៥។ ពួកគាត់ ក៏បានរៀបរាប់ពីតួនាទីនិងការងាររបស់ពួកគាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ លោក ស វិ ជាទាហានការពារនៅ មន្ទីរ ក-១ និង លំនៅដ្ឋានប្រចាំរបស់ ប៉ុល ពត ចំណែកឯ លោក អ៊ុង រ៉ែន និង លោក ឆោម សែ ត្រូវបានចាត់តាំងឲទៅខាងព្យួសានធ្វើជាទាហាននៅក្នុង កងពល ៨០១ ហើយ លោក ឆោម សែ ជាប្រធានមន្ទីរសន្តិសុខអូរកន្សែង។

ក្នុងកិច្ចដំណើរការសួរដេញដោលសាក្សីទាំងនេះ មិនមានការលើកឡើងពីសេចក្តីជំទាស់ច្រើនទេ ។ ក្នុងសប្តាហ៍នេះ បញ្ហាច្បាប់និងនីតិវិធី ត្រូវបានលើកឡើងពាក់ព័ន្ធនឹងការប្រើប្រាស់សំណួររបស់ព្រះរាជអាជ្ញាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ និង ភាពទទួលយកបាននៃតវិយាបថស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ជាពិសេសចំពោះបទសម្ភាសន៍ជាមួយសាក្សី អ៊ុង រ៉ែន។ អង្គជំនុំជម្រះសាលាដំបូង ក៏បានប្រកាសដែរថា វានឹងធ្វើឲមានការអូសបន្លាយពេលវេលាក្នុងការកោះហៅ TCCP-94 ក្រោយពីមានការបើកកកាយថា ដើមបណ្តឹងរដ្ឋប្បវេណី មិនមានចំណេះដឹងផ្ទាល់ពីការជម្លៀសប្រជាជនចេញពីភ្នំពេញ។

## II. សង្ខេបសក្ខីកម្មរបស់ សាក្សី

នាសប្ដាហ៍នេះ សាក្សីទាំង៣រូប បានផ្ដល់សក្ខីកម្មពីបទពិសោធន៍របស់ពួកគាត់នៅមុនពេល ក្នុងអំឡុងពេល និង ក្រោយពេលភ្នំពេញត្រូវបានវាយបែកក្នុង ខែ មេសា ឆ្នាំ ១៩៧៥។ លោក ស រី លោក អ៊ឹង វ៉ែន និង លោក ឆោម សែ បានផ្ដល់ព័ត៌មានយ៉ាងលម្អិតពីរចនាសម្ព័ន្ធនិងតួនាទីយោធា ក្នុងពេលដែលពួកគាត់ បានពណ៌នាពីហេតុផលក្នុងការចូលរួមចលនាបដិវត្តន៍ ក៏ដូចជា ការឈរជើងត្រៀមនៅតាមតំបន់ជាច្រើន និង ការឡើងតំណែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

## ក. សក្ខីកម្ម ស ខ

លោក ស រី គឺជាសាក្សីទី១ ដែលបានផ្ដល់សក្ខីកម្មមុនគេ សម្រាប់ការបើកសវនាការឡើងវិញក្នុងឆ្នាំ២០១៣។ គាត់ ជាកសិករចំណាស់ម្នាក់មានអាយុ៥២ឆ្នាំ រស់នៅប៉ៃលិន។[2] ដំបូងឡើយ គាត់បានរំឭកពីបទពិសោធន៍របស់គាត់ ជាអ្នកការពារ *"ជាន់ទី២"* នៃមន្ទីរក-១ ដែលជាលំនៅដ្ឋានប្រចាំរបស់ ប៉ុល ពត ក្នុងភ្នំពេញ។ លោក ស រី បានចាំពីទស្សនៈកិច្ចរបស់ជនជាប់ចោទ ស្ថានភាពតាមជាន់នៃអាគារ និង ការបាត់ខ្លួនបណ្ដោះអាសន្ន និង ការបាត់ខ្លួនរហូតរបស់កម្មាភិបាលរួមការងារ។

### ១. បទពិសោធន៍មុនពេលចូលបម្រើការងារនៅ ក-១

ម៉ន ត្រូវជាពូរបស់ លោក ស រី បាននាំគាត់ចូលធ្វើបដិវត្តន៍នៅដើមទសវត្ស ១៩៧០ ហើយបន្តិចក្រោយមក គាត់បានចាប់ផ្ដើមការងារជានីរសារម្នាក់ នៅតាមឃុំក្នុងស្រុកសំរោង ខេត្តកំពង់ស្ពឺ។ សាក្សីបាននិយាយថា ក្នុងឆ្នាំ១៩៧៥ គាត់បានក្លាយជាទាហានប្រចាំស្រុកសំរោង និង ក្រោយមកត្រូវបានឡើងតំណែងទៅថ្នាក់តំបន់ ដែលរាប់បញ្ចូលស្រុកសំរោង និង ស្រុកកងពិសី។[3] លោក ស រី បានពន្យល់ថា ស្រុកកងពិសី មិនទាន់បានរំដោះទាំងស្រុងនៅឡើយទេនៅឆ្នាំ១៩៧៣ ប៉ុន្តែ នៅឆ្នាំ ១៩៧៤ ការទម្លាក់គ្រាប់បែកត្រូវបានបញ្ឈប់ ហើយទាហាន លន់ ណុល ក៏ឈប់ដើរល្បាតតំបន់នេះផងដែរ ដែលបណ្ដាលឲ គាត់បានសន្និដ្ឋានថា ស្រុកកងពិសី ត្រូវបានរំដោះទាំងស្រុង។

ក្រោយ ១៧ មេសា ១៩៧៥ សាក្សី បានប្រាប់ថា គាត់បានសង្កេតឃើញប្រជាជនត្រូវបានជម្លៀសទៅស្រុកកងពិសី។ គាត់បានពន្យល់ថា ប្រជាជនខ្លះ បានធ្វើដំណើរតាមឡាន ឬ ទោចក្រយានយន្ត ប៉ុន្តែភាគច្រើនដោយថ្មើរជើង។ ពេលមកដល់ស្រុកកងពិសី មេឃុំ និង កម្មាភិបាលផ្សេងទៀត បានណែនាំប្រជាជនឲស្នាក់នៅតាមកន្លែងផ្សេងៗគ្នាក្នុងតំបន់នេះ។ យោងតាម លោក ស រី អ្នកជម្លៀសទាំងនោះមិនត្រូវបានគេបំបែកចេញពីគ្រួសារ ឬតាមដានពីខ្សែបណ្ដាញជាមួយរដ្ឋាភិបាល លន់ ណុល ទេ។ ទោះបីជាមិនអាចស្មានដឹងពីចំនួនមនុស្សឲជាក់លាក់ សាក្សីបាននិយាយថា គាត់បានឃើញមនុស្សជាច្រើនបានមកដល់តំបន់របស់គាត់នៅឃុំពោះអង្រ្កងរយៈពេល៣ថ្ងៃ។ គាត់មិនបានឃើញមានទាហានយាមកាមពួកគេឡើយ ប៉ុន្តែ គាត់ក៏មិនបានឃើញមានអ្នកណាផ្ដល់បាយទឹក ឬថ្នាំសង្កូវឲអ្នកជម្លៀសផងដែរ។ ពេលមកដល់ប្រជាជនជម្លៀសទាំងនេះ បានបោះជំរុំនៅតាមវត្តអារ៉ាម សាលារៀន ឬផ្ទះអ្នកស្រុក។ សាក្សីបានអះអាងថា

វត្តអារ៉ាមនាពេលនោះ បានឈប់ដំណើរការហើយ ហើយគាត់បានដឹងពីអ្នកភូមិថា ព្រះសង្ឃទាំងអស់បាន *"សឹកតាំងពីជំនាន់សង្គ្រាមឆ្នាំ៧៣, ៧៤។"*[4]

លោក ស វី បាននិយាយជាច្រើនដងថា គាត់ជា *"យុទ្ធជនធម្មតា។"* គាត់បានពន្យល់ថា ក្នុងនាមជាយុទ្ធជនម្នាក់ តួនាទីរបស់គាត់ គឺធ្វើការងារហត្ថកម្ម ជាពិសេស ជីកប្រឡាយ និង កសាងទំនប់ទឹក។ ប៉ុន្តែគាត់បានឲយោបល់ថា ទាហានធ្វើការនៅផ្នែកផ្សេងៗដាច់ដោយឡែកពីប្រជាជន។

## ២. បេសកម្មនៅ ក-១ និង រចនាសម្ព័ន្ធអ្នកការពារ

នៅចុងឆ្នាំ១៩៧៥ ឬ ដើមឆ្នាំ១៩៧៦ លោក ស វី បានថ្លែងថា គាត់ត្រូវបានចាត់តាំងឲធ្វើការនៅ ក-១ ស្ថិតនៅភ្នំពេញ រហូតដល់ គាត់ បានភៀសខ្លួនចេញពីភ្នំពេញជាមួយថ្នាក់ដឹកនាំនិងកម្មាភិបាលនៅក្នុងឆ្នាំ១៩៧៩។ គាត់ បានពន្យល់ថា ក-១ ជាលំនៅដ្ឋានប្រចាំរបស់ ប៉ុល ពត ហើយមានទីតាំងនៅឆ្ងាយពីព្រះបរមរាជវាំងពីទិសខាងត្បូង១គីឡូម៉ែត្រ។ សាក្សី បាននិយាយម្តងហើយម្តងទៀតថា អង្គភាពការពារមាន ៣ *"ជាន់"*[5] ៖ ជាន់ទី១ នៅខាងក្នុងបំផុត ដែលហ៊ុំព័ទ្ធដោយរបងក្តារ និង លួសការពារព័ទ្ធជុំវិញ ជាន់ទី២ មានរបងក្តារ និង ៤ប៉ុស្តិ៍ ឬប៉ម ក៏ដូចជាទ្វារធំមួយបើកសម្រាប់អ្នកមកធ្វើទស្សនៈកិច្ច ដែលត្រូវបានត្រួតពិនិត្យនៅបរិវេណទី៣ ចម្ងាយប្រហែលជា២គីឡូម៉ែត្រពីអាគារ។ ទោះបីជាគាត់មិនបានដឹងច្បាស់ពីចំនួនអ្នកការពារនៅបរិវេណទី៣ក៏ដោយ លោក ស វី បានប៉ាន់ស្មានថា មានអ្នកការពារប្រហែលជា១០នាក់ ឈរជើងនៅបរិវេណទី១ និង គាត់ដឹងច្បាស់ថា មានអ្នកការពារពី៥០ទៅ៦០នាក់ នៅបរិវេណទី២ ដែលជាកន្លែងគាត់ឈរជើង។

សាក្សី បាននិយាយថា មេផ្ទាល់របស់គាត់នៅ ក-១ មានឈ្មោះថា តាន ហៅ *ខៀវ* ជាអ្នកមើលការខុសត្រូវលើ មេក្រុម និង មេកង។ ប៉ង់ អ្នកដែលទទួលបញ្ជាពី ប៉ុល ពត និង ជាអ្នកមើលការខុសត្រូវអ្នកការពារប្រចាំ ក-១ ហើយក្រោយមក គាត់ត្រូវបានជំនួសដោយ កែន ហៅ លិន។ តាន និង សុត បានទទួលបញ្ជាពី ប៉ង់ និង ក្រោយមក កែន ហើយក៏មានបញ្ជាផ្ទាល់ពី ប៉ុល ពត និង **នួន ជា** ម្តងម្កាលដែរ។ ប៉ុន្តែ គាត់នៅតែមិនច្បាស់ ដែលថា ប៉ង់ បានធ្វើការជិតស្និតជាមួយជនជាប់ចោទ និង ប៉ុល ពត ដោយរបៀបណានោះទេ។ លោក អាកទួរ វែកគែន មេធាវីអន្តរជាតិឲ លោក **ខៀវ សំផន** បានសួរផ្ទាញ់ លោក ស វី នឹងអង្គហេតុដែលថា បុគ្គលម្នាក់ឈ្មោះ អឿន តាន ហៅ ជូ បានធ្វើសក្ខីកម្មចំពោះមុខតុលាការ ហើយអះអាងថាមិនបានស្គាល់សាក្សី លោក ស វី ទេ។[6] សាក្សី បានឆ្លើយតបថា គាត់រក្សាចម្លើយរបស់គាត់ក្នុងកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ដែលគាត់បាននិយាយថា គាត់ បាននៅជាមួយ តាន ចាប់ពី ឆ្នាំ ១៩៧៦ ដល់ ឆ្នាំ ១៩៩៦ ហើយ អឿន តាន ច្បាស់ជាមានហេតុផលផ្ទាល់ខ្លួនណាមួយ ក្នុងការបដិសេធមិនស្គាល់គាត់។

លោក ស វី បាននិយាយថា គាត់បានចូលប្រជុំស្វ័យទិតៀន ដែលធ្វើដោយថ្នាក់ដឹកនាំការិយាល័យជារៀងរាល់ខែ ដែលជារឿយៗ តាន ជាវាលគ្មិន។ សាក្សីបានពន្យល់ថា កិច្ចប្រជុំភាគច្រើនបានផ្តោតសំខាន់ពីរបៀបបំពេញតួនាទីឲបានល្អ ដូច្នេះ មិត្តរួមការងារ ត្រូវបានគេឲរិះគន់គ្នាទៅវិញទៅមកដើម្បីកុំឲមានកំហុសកើតឡើងដដែលៗ។ ក្នុងពេលកិច្ចប្រជុំស្វ័យតិទៀន មានការលើកឡើងជាញឹកញាប់ពីការគំរាមកំហែងសន្តិសុខ ប៉ុន្តែសាក្សីបានរក្សាជំហរថា ពេលដែលគាត់ធ្វើជាអ្នកការពារ មិនមានការប៉ុនប៉ង វាយប្រហារមក

លើការិយាល័យមួយនេះទេ។ លោក ស វិ បានបញ្ជាក់ថា គាត់មិនអាចចាំបានអ្វីទាំងអស់នៅក្នុងកិច្ចប្រជុំទាំងនេះ ទាក់ទងនឹងការស៊ើបអង្កេតរកខ្មាំងក្នុងជួរ ដែលពាក់ព័ន្ធនឹង សេ.អ៊ី.អា. កា.ហ្សេ.បេ. ឬយួនទេ។ នៅក្នុងវគ្គសិក្សាអប់រំ និយមន័យ *"ខ្មាំង"* ជាប់ពាក់ព័ន្ធនឹងខ្មាំងមានកាន់អាវុធច្រើនជាង ព្រោះ ពពួកនេះអាចវាយប្រហារមកលើការិយាយល័យនេះ។ ពេលគាត់កំពុងធ្វើការនៅ ក-១ សាក្សី បានចូលរួមពិធីអបអរសាទរចូលឆ្នាំថ្មី និង ការរំឭកខួបរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុង *"ស្តាតចាស់"*។ គាត់បានអះអាងថា គាត់មិនដែលបានឃើញថ្នាក់ដឹកនាំកំពូលក្នុងព្រឹត្តការណ៍ទាំងនេះទេ ប៉ុន្តែ មានតែយុវជន និង យុទ្ធជន ទេដែលបានចូលរួមសប្បាយ។

## ៣. ទំនាក់ទំនងជាមួយថ្នាក់ដឹកនាំកំពូល។

នៅ ក-១ លោក ស វិ បានបញ្ជាក់ថា គាត់ បានឃើញថ្នាក់ដឹកនាំកំពូលៗជាទៀងទាត់ រួមទាំង លោក **អៀង សារី** លោក **នួន ជា** និង លោក **ខៀវ សំផន** ក្នុងខណៈដែលពួកគេបានចេញចូល ក-១ នៅក្នុងឡានរបស់ពួកគេ។ សាក្សី បានអះអាងថា គាត់បានស្គាល់ សុត និង សឿន ដោយផ្ទាល់ ព្រោះអ្នកទាំងពីរជាអ្នកបើកបរឲ លោក **នួន ជា** និង លោក **ខៀវ សំផន**។ យោងតាម សាក្សី លោក **ខៀវ សំផន** បានធ្វើទស្សនៈកិច្ចមកកាន់ ក-១ ញឹកញាប់ជាងថ្នាក់ដឹកនាំផ្សេងទៀត ហើយតែងតែជិះឡានមិនសូវទំនើប ដោយមានអ្នកអមតែម្នាក់គត់ គឺអ្នកបើកឡានឲគាត់។ ការិយាល័យ ក-១ ក៏មានបើកវគ្គសិក្សារៀនសូត្រ ដែលចូលរួមដោយថ្នាក់ដឹកនាំគណៈតំបន់និងភូមិភាគផងដែរ។ សាក្សី បានយល់ដឹង ពីកិច្ចប្រជុំទាំងនេះ ពេលដែលអ្នកយាមការពារនៅបរិវេណទី២ បានទទួលបញ្ជាឲសម្អាតផ្លូវ និង ការពារថ្នាក់ដឹកនាំទាំងនោះ។ ប៉ុន្តែ ខ្លួនគាត់ផ្ទាល់មិនបានដឹងពីប្រធានបទនៃកិច្ចប្រជុំនេះទេ ហើយទោះបីជា គាត់បាន អះអាងថាមិនបានដឹងឈ្មោះអ្នកចូលរួមទាំងនោះក៏ដោយ លោក ស វិ បាននិយាយថា គាត់បានឮឈ្មោះអ្នកចូលរួម២នាក់គឺ សោ ភឹម មកពីភូមិភាគបូព៌ា និង តា ម៉ុក មកពីភូមិភាគនិរតី ពីអ្នកយាមការពារនៅបរិវេណទី១។

ថ្នាក់ដឹកនាំទាំងនេះ បានចាកចេញពី ក-១ ម្តងម្កាលដើម្បីចូលរួមប្រជុំ ឬធ្វើទស្សនៈកិច្ចតាមខេត្ត។ លោក ស វិ បានបញ្ជាក់ថា គាត់ បានទៅហែហមតាម ប៉ុល ពត បានម្តង ពេលពួកថ្នាក់ដឹកនាំទៅវគ្គសិក្សាអប់រំមួយនៅបុរីកីឡា។ សាក្សី បានដឹងពីទស្សនៈកិច្ចមួយផ្សេងទៀតរបស់មេដឹកនាំទៅតាមខេត្ត ពីអ្នកយាមការពារម្នាក់ ដែលត្រូវបានចាត់តាំងឲរួមដំណើរជាមួយពួកគាត់។ ក្នុងពេលធ្វើសក្ខីកម្ម សាក្សី បានសារៈភាពថា សេចក្តីថ្លែងការណ៍របស់គាត់មួយចំនួនទៅកាន់ចៅក្រមស៊ើបអង្កេតស្តីពីការធ្វើដំណើររបស់ មេដឹកនាំ គឺយោងតាមការសង្កេតការណ៍ផ្ទាល់ខ្លួនរបស់គាត់ ជាជាងអង្គហេតុជាក់ស្តែង។[7] លោក ស វិ បានថ្លែងថា ពេលត្រឡប់មកពីទស្សនៈកិច្ចទាំងនេះ តាន និង សុត បានប្រាប់គាត់ថា ប្រជាជនមានម្ហូបអាហារបរិភោគបានប្រសើរនៅតាម *"មូលដ្ឋាន"*។ សាក្សី បានពន្យល់ថា គាត់គ្រាន់តែបានដឹងពីគ្រោះទុរ្ភិក្ស ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យនៅលើកទី១ ក្នុងឆ្នាំ១៩៨២ តាមវិទ្យុ។

លោក ស វិ បានពន្យល់ថា អ្នកយាមការពារ ដែលបានប្រព្រឹត្តកំហុសតិចតួចញឹកញាប់ ដូចជាដេកពេលម៉ោងយាម នឹងត្រូវបានគេយកទៅអប់រំកែប្រែ ហើយប្រសិនបើពួកគេនៅតែមិនកែកំហុសទៀត ពួកគេនឹងត្រូវបញ្ជូនចេញពី ក-១។ សាក្សី មិនបានដឹងពីអ្វីដែលបានកើតឡើងមកលើពួកអ្នកទាំងនោះទេ បន្ទាប់ពីត្រូវបានផ្ទេរចេញ។ គាត់ បានបញ្ជាក់ថាបានជួបអ្នកយាមទាំងនោះខ្លះៗ នៅពិធីអបអរសាទរនៅ

ស្អាតចាស់ ហើយក៏ដូចជាក្រោយឆ្នាំ១៩៧៩។ តាមរយៈសាក្សី ពួកគេមិនដែលនិយាយពីការប្រព្រឹត្តអំពើព្រៃផ្សៃទេ។ ប៉ុន្តែ នៅក្នុងសក្ខីកម្មរបស់គាត់ លោក ស រី បានទទួលស្គាល់ថា មានមនុស្សមួយចំនួន បានបាត់ខ្លួនពី ក-១ ហើយឈ្មោះរបស់ពួកគេ ត្រូវបាននិយាយរិះគន់ជាបន្តបន្ទាប់ ដោយចោទថាជាជនក្បត់។[8] សាក្សីបានអះអាងថា គាត់មិនបានដឹងថាអ្នកណាមានអំណាចចេញបញ្ជាឲចាប់ខ្លួនកម្មាភិបាលទេ។ នៅក្នុងចម្លើយរបស់គាត់ទៅកាន់សំណួរក្នុងបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ដែលគាត់បាននិយាយជាក់លាក់ពីការដឹងឮរបស់ ប៉ុល ពត និង លោក **នួន ជា** ពាក់ព័ន្ធនឹងការចាប់ខ្លួនទាំងនេះ។ នៅចំពោះមុខតុលាការគាត់ផ្តល់ សក្ខីកម្មថា ឥឡូវនេះ គាត់ មិនច្បាស់ពីតួនាទីរបស់ លោក **នួន ជា** និង លោក **អៀង សារី** នៅក្នុងបញ្ហានេះ ទេ។ លោក ស រី ក៏បាននិយាយដដែលៗថា ការយល់ឃើញផ្ទាល់របស់គាត់ពី លោក ខៀវ សំផន គឺថា ជនជាប់ចោទតែងតែមាន *"ការគិតច្រើន"* និង *"ភាពម៉ត់ចត់ ម៉ឺងម៉ាត់"* ពីការងារ។

## ៤. ការជាប់ទាក់ទងជាមួយខ្មែរក្រហមក្រោយ ១៩៧៩

នៅថ្ងៃ ៧ មករា ១៩៧៩ លោក ស រី បានភៀសខ្លួនជាមួយ ប៉ុល ពត លោក **នួន ជា** និង លោក **ខៀវ សំផន** ចេញពីភ្នំពេញទៅកាន់ព្រំដែនថៃ។ នៅខែ ឧសភា ឆ្នាំ ១៩៧៩ គាត់ បានចូលប្រជុំកងអង្គរក្សមួយដឹកនាំផ្ទាល់ដោយ ប៉ុល ពត តែម្នាក់គត់នៅលើភ្នំក្រវាញ។ ក្នុងកិច្ចប្រជុំនេះ សាក្សី បានឮ ប៉ុល ពត និយាយថា ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យចាប់ពី ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ បានមានកំហុស ហើយទោះបីជាពួកគាត់ មិនបានបញ្ជាឲសម្លាប់និងធ្វើទារុណកម្មក៏ដោយ ក៏មេដឹកនាំទាំងនេះ ត្រូវតែមានទំនួលខុសត្រូវចំពោះបញ្ហានេះ ក្នុងឋានៈជាថ្នាក់ដឹកនាំក្នុងអំឡុងពេលនោះ។ សាក្សី បានស្នាក់នៅជាមួយមេដឹកនាំទាំងបីនេះ រហូតដល់ពួកគេផ្លាស់ទៅ អន្លង់វែង ចំណែកគាត់ បានសម្រេចចិត្តបន្តនៅប៉ៃលិន។

សាក្សី បានមានអារម្មណ៍ថា រដ្ឋបាលនិងការគ្រប់គ្រងរបស់ខ្មែរក្រហម បានផ្លាស់ប្តូរក្រោយពេលវៀតណាមវាយចូល។ គាត់ បានសារៈភាពថា គាត់ជាក្មេងជំទង់ម្នាក់ ដែលមិនសូវដឹងរាក់ជ្រៅពីបញ្ហារដ្ឋបាលនៅភ្នំពេញ ក្នុងកំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ យ៉ាងណាក្តី គាត់បានអះអាងថា ក្រោយពេលថ្នាក់ដឹកនាំទាំងនេះ បានបាត់បង់អំណាចក្នុង ឆ្នាំ ១៩៧៩ ហើយភៀសខ្លួនចេញពីរាជធានីភ្នំពេញ ជីវិតរបស់ពួកគាត់បានប្រែប្រួល ហើយគោលនយោបាយអាទិភាពក្នុងការកសាងសហករណ៍ក៏បានផ្លាស់ប្តូរទៅជាការតស៊ូរស់នៅក្នុងព្រៃ និងរួបរួមគ្នាប្រឆាំងនឹងរដ្ឋាភិបាលថ្មីដើម្បីសង្គ្រោះជាតិ។

## ៥. ឥរិយាបថ និង ភាពជឿជាក់របស់សាក្សី

ក្នុងសក្ខីកម្មរបស់គាត់ លោក ស រី បានផ្តល់ចម្លើយស៊ីសង្វាក់គ្នាល្អ ហើយ គាត់ បានដឹងមុនជាស្រេចថា សក្ខីកម្មរបស់គាត់ភាគច្រើន ជាពិសេសចំណេះដឹងពាក់ព័ន្ធនឹងថ្នាក់ដឹកនាំកំពូលនៃរបបកម្ពុជាប្រជាធិប-តេយ្យ បានផ្អែកលើការសន្និដ្ឋានផ្ទាល់របស់គាត់ ជាជាងអង្គហេតុជាក់ស្តែង។ គាត់ បានអះអាងប្រកាន់យកចម្លើយមុនៗរបស់គាត់ទៅកាន់អ្នកស៊ើបអង្កេត ទោះបីជា គាត់ត្រូវបានដាក់ប្រឈមប្រៀបធៀបនឹងចម្លើយរបស់សាក្សីផ្សេងៗទៀត ដែលព្យាយាមបន្ទាបតម្លៃនៃការយល់ឃើញរបស់គាត់។

## ខ. សក្ខីកម្ម អ៊ុង រ៉េន

លោក អ៊ុង រ៉េន ជាកសិករចំណាស់ម្នាក់មានអាយុ ៦៣ ឆ្នាំ មកពី ត្រពាំងប្រសិទ្ធិ៍ បានចូលមកធ្វើសក្ខីកម្មក្នុងសប្តាហ៍នេះ ពីភាពពាក់ព័ន្ធរបស់គាត់ក្នុងជួរទាហានខ្មែរក្រហមតាំងពី ឆ្នាំ ១៩៧០។[9] សក្ខីកម្មរបស់គាត់ បានជាប់ទាក់ទងនឹងការចាប់ទាហាន លន់ ណុល នៅមុន ឆ្នាំ ១៩៧៥ ការជម្លៀសប្រជាជនចេញពីភ្នំពេញ និង កិច្ចការងាររបស់គាត់នៅ កងពល ៨០១ នៅភូមិភាគឦសាន។ លោក អ៊ុង រ៉េន អាចផ្តល់ព័ត៌មានលម្អិតពី សុន សេន និង ប៉ុល ពត ក្នុងរចនាសម្ព័ន្ធយោធាក្នុងជួរកងទ័ព។

### ១. បទពិសោធន៍មុនឆ្នាំ ១៧ មេសា ១៩៧៥

បន្ទាប់ពីការអំពាវនាវរបស់ **សម្តេច សីហនុ** ក្នុង ឆ្នាំ ១៩៧០ សាក្សី បានចូលចលនាបដិវត្តន៍នៅភូមិ ត្នាតពង ខេត្តកំពង់ស្ពឺ ហើយបានក្លាយជាសមាជិកម្នាក់នៃជួរកងទ័ពភូមិភាគពិសេស។ ពេលឆ្លើយតបនឹងសំណួររបស់ព្រះរាជអាជ្ញាជាតិ សុង ឆវ័ន្ត លោក អ៊ុង រ៉េន បានពន្យល់ថា កងទ័ពភូមិភាគពិសេសបានរាយការណ៍ទៅ អេង ចន[10] ហើយ *"ខំប្រមូលកម្លាំងដើម្បីរួបរួមគ្នា ឲមានកម្លាំងច្រើន។"*[11] កងពលដំបូងរបស់គាត់ ត្រូវបានបញ្ចូលរួមជាមួយកងពលមួយផ្សេងទៀត ដើម្បីបង្កើតកងវរសេនាធំក្នុង ឆ្នាំ ១៩៧២ ដែលក្រោយៗមក ត្រូវបានបញ្ចូលបន្តទៀតជាមួយកងពលផ្សេងទៀតក្លាយទៅជាកងពលតូចលេខ១៤ ដែលដឹកនាំដោយ ស៊ូ សារឿន ហៅ ០៥។ នៅចំនុចនេះ លោក អ៊ុង រ៉េន ត្រូវបានតំឡើងតំណែងជាមេបញ្ជាការកងវរសេនាធំ គ្រប់គ្រងមនុស្ស៥០០នាក់។ សាក្សី បានបញ្ជាក់ថា កងវរសេនាធំរបស់គាត់ បានវាយប្រហារទាហាន លន់ ណុល នៅជិតភ្នំបាសិត។ ឈ្លើយសឹក ត្រូវបាន*"បញ្ជូនទៅក្រោយ"*ហើយក្រោយៗមក គាត់មិនបានដឹងថាមានហេតុការណ៍អ្វីកើតឡើងចំពោះអ្នកទាំងនោះទេ។ ពេលដែលគាត់បញ្ជាក់ថាកងវរសេនាធំរបស់គាត់បានប្រយុទ្ធក្នុងសមរភូមិនៅឧត្តុង្គ ឆ្នាំ ១៩៧៤ លោក អ៊ុង រ៉េន បានអះអាងថា កងកម្លាំងយោធាទាំងនោះ មិនមែនមកពីកងវរសេនាធំរបស់គាត់ទេ ប៉ុន្តែមកពីខាងនិរតីវិញ។ សាក្សី បាននិយាយថា ស៊ូ សារឿន ដែលជាមេបញ្ជាការកងពលតូច និង ចេន អន បានរៀបចំគម្រោងការវាយលុកនេះ។ គាត់បានដឹងពីផែនការនេះក្នុងកិច្ចប្រជុំមួយនៅតាមផ្លូវទៅឧត្តុង្គ។

### ២. ការត្រៀមវាយរំដោះភ្នំពេញ និង ការជម្លៀសជាបន្តបន្ទាប់

ក្រោយពេលវាយបែកឧត្តុង្គ និង ការជម្លៀសជាបន្តបន្ទាប់ ដែលសាក្សីបានអះអាងថាមិនបានដឹងពីបញ្ហានេះ មានបទបញ្ជាពីមេបញ្ជាការកងពលតូចថា *"មានការដឹកនាំនៅអង្គភាពខាងទិសរបស់ភូមិភាគនិរតីហើយ។"*[12] លោក អ៊ុង រ៉េន បានបញ្ជាក់ចម្លើយរបស់គាត់ទៅកាន់ចៅក្រមស៊ើបអង្កេតថា សុន សេន ហៅ *ខៀវ* បានដឹកនាំប្រជុំមួយក្នុងខេត្តកំពង់ស្ពឺដើម្បីត្រៀមរៀបចវាយប្រហារភ្នំពេញភ្លាមៗ។ កិច្ចប្រជុំត្រូវ បានធ្វើឡើង*"នៅតាមគុម្ពឫស្សី"* ដែលមានការចូលរួមពីតំណាងមកពី កងពលតូច កងវរសេនាធំ និង កងវរសេនាតូច។ សាក្សី មិនបានដឹងពីផែនការជម្លៀសប្រជាជនចេញពីភ្នំពេញទេ ដោយបានទទួចថា សុន សេន និយាយតែរឿង *"វ៉ៃទៅមុខរំដោះភ្នំពេញ។"*

លោក អ៊ុង វ៉ែន បានពន្យល់ថា កងវរសេនាធំរបស់គាត់ បានចូលតាមច្រកពោធិ៍ចិនតុង រីឯ កងកម្លាំងនិរតីវាយចូលតាមផ្លូវជាតិលេខ៤។ ក្នុងពេលសមរភូមិនេះ សាក្សី បានត្រូវរបួសនិងដេកពេទ្យនៅមន្ទីរពេទ្យតាំងកសាង រហូតដល់វាយបែកភ្នំពេញទាំងមូល។[13] ដំបូង គាត់ បានឃើញហ្វូងប្រជាជន បានកំពុងចាកចេញភ្នំពេញតាមថ្មើរជើងដោយមានអីវ៉ែអីវ៉ាន់នៅលើរទេះរុញ ក្នុងខណៈ គាត់កំពុងព្យាបាលរបួសនៅមន្ទីរពេទ្យនៅឡើយ។ គាត់ បានថ្លែងថា គាត់មិនបានឃើញមានអ្នកណាបង្ខំប្រជាជនឲជម្លៀសចេញទេ ទោះបីជាគាត់បានសម្ដែងមន្ទិលសង្ស័យថា *"ផ្ទះគាត់ ភូមិគាត់ ស្រុកគាត់ ដូច្នេះគាត់ចង់ទៅធ្វើអីគាត់។ ដូច្នេះ ទាល់តែបង្ខំទាល់តំរាមកំហែង បានគាត់ទៅ។"*[14] លោក អ៊ុង វ៉ែន បាននិយាយថា ទាហានម្នាក់ បានប្រាប់គាត់ថាហេតុផលក្នុងការជម្លៀសប្រជាជន គឺដើម្បីការពារពីការវាយប្រហាររបស់ខ្មាំង ដែលនៅលាយឡំជាមួយប្រជាជន និង ដើម្បីជៀសវៀងពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំង។ សាក្សី បានបដិសេធពីការបង្កើតផែនការណ៍បំបែកនិងបែងចែកទាហាន និង មន្ត្រីនៃរបប លន់ ណុល ទោះបីជាគាត់បានរំឭកតុលាការថា គាត់បានដេកពេទ្យនៅពេលនោះ។

## ៣. ការដាក់ពង្រាយទ័ព និង រចនាសម្ព័ន្ធរាយការណ៍នៃកងពល ៨០១

ក្នុងពេលត្រូវបានសួរដេញដោលដោយព្រះរាជអាជ្ញាជាតិ សុង ឆវ័ន្ត សាក្សី បានបដិសេធមិនបានដឹងពីការធ្វើសមាជ ដែលបានចូលរួមដោយមនុស្សរាប់ពាន់នាក់នៅ ២២ កក្កដា ១៩៧៥។ គាត់ គ្រាន់តែចាំបានពីកិច្ចប្រជុំធ្វើនៅ *"ពហុកីឡដ្ឋាន"* ដែលមានការប្រកាសថា កងពលតូចលេខ១៤ នឹងត្រូវបានបង្កើតឡើងវិញជា កងពល៨០១ និងត្រូវបានដាក់ពង្រាយនៅខាងល្វសាន។[15] នៅក្នុងបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ដកស្រង់ដោយព្រះរាជអាជ្ញាជាតិរូបនេះ សាក្សី បានថ្លែងថា ប៉ុល ពត- **នួន ជា- អៀង សារី- ខៀវ សំផន** និង សុន សេន បានមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ។ ប៉ុន្តែ នៅក្នុងសក្ខីកម្មរបស់គាត់ចំពោះមុខតុលាការ លោក អ៊ុង វ៉ែន បានដកឈ្មោះ **ខៀវ សំផន** ចេញពីឈ្មោះពាក់ព័ន្ធទាំងនេះ។ គាត់ ក៏បានបញ្ជាក់ថា ប៉ុល ពត ខ្លួនគាត់ផ្ទាល់ *"ប្រគល់ភារកិច្ចឲកងពល៨០១"* ហើយប្រកាសបញ្ជូនកងពល៨០១ ទៅខេត្តរតនគិរី។ សាក្សី បានបកស្រាយថា វាជាលើកទីមួយហើយដែលគាត់ បានជួប ប៉ុល ពត។ នាពេលនោះ អ្នករាល់គ្នាបានសំដៅ ប៉ុល ពត ថាជា *"បងទី១"* នួន ជា ជា *"បងទី២"* ប៉ុន្តែ គាត់មិនបានដឹងពីឋានៈរបស់មេដឹកនាំផ្សេងទៀតឡើយ។

លោក អ៊ុង វ៉ែន បានថ្លែងថា មានទាហានជាង ៥០០០ នាក់ នៅក្នុងកងពល៨០១ ក្រោមបញ្ជារបស់ ស៊ូ សារឿន។ សាក្សី បានពន្យល់ថា ក្នុងកងពល មានកងវរសេនាធំៗ ហើយក្នុងកងវរសេនាធំ មានកងវរសេនាតូច៣ និង ៣ផ្នែកផ្សេងទៀតដូចជា ភ័ស្តុភារ យោធា និង នយោបាយ។ នៅក្នុងកងវរសេនាតូចមានកងអនុសេនាតូច៣ ហើយក្នុងកងអនុសេនាតូច មានកងតូចៗ៣ទៀត ដែលកងតូចនេះមានទាហានប្រហែលជា៣៥នាក់។ សាក្សី បានពន្យល់ថា គាត់បានរាយការណ៍ផ្ទាល់ទៅ ស៊ូ សារឿន ពេលគាត់ បានធ្វើជាមេបញ្ជាការកងវរសេនាធំ មានទាហានក្រោមបញ្ជាប្រហែល៤៣០នាក់ ឈរជើងនៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ជិតទល់ដែនប្រទេសឡាវ។[16] ប៉ុន្តែ លោក អ៊ុង វ៉ែន បានពន្យល់ថា គាត់ មិនបានដឹងពីប្រភពដើមនៃបញ្ជារបស់ ស៊ូ សារឿន ទេ។

លោក អ៊ុង រ៉ែន បាននិយាយថា គាត់ មិនបានយល់ដឹងពីប្រព័ន្ធរាយការណ៍ ឬភាពញឹកញាប់នៃរបាយការណ៍នៅកំរិតកងពលទេ។ គាត់ គ្រាន់បានរាយការណ៍ទៅមេបញ្ជាការកងពល អ្នកដែលមិនចាំបាច់ប្រឹក្សា ហើយចាំទទួលការឆ្លើយតបរបស់លេខាភូមិភាគទេ។ មុនពេលភ្នំពេញរលំ គាត់ បានបកស្រាយថា របាយការណ៍ត្រូវបានធ្វើសម្រាប់តែ សុន សេន ម្នាក់គត់។ ក្រោយពេលដាក់ពង្រាយកងពល៨០១ បញ្ជាយោធាត្រូវបានរាយការណ៍ទៅ សុន សេន រីឯ បញ្ជានយោបាយត្រូវផ្ញើទៅ ប៉ុល ពត។[17] សាក្សី បានរៀបរាប់ថា វាមានភាពលំបាកក្នុងការធ្វើទំនាក់ទំនងនៅតាមតំបន់ដាច់ស្រយាលព្រៃស្ងាត់ ដោយសារតែអង្គភាពនីមួយៗនៅឆ្ងាយពីគ្នាក្នុងកងពល៨០១។ ពួកគេមានម៉ាស៊ីនទូរលេខ ដែលដំណើរការម្តងម្កាលតែប៉ុណ្ណោះ បើមិនដូច្នោះទេ នឹងត្រូវធ្វើដំណើរថ្មើរជើង៤ឬ៥ថ្ងៃ ដើម្បីបញ្ជូនព័ត៌មាន។ ប្រសិនបើមិនមានអ្វីបន្ទាន់នោះទេ ពួកគេនឹងធ្វើជារបាយការណ៍ប្រចាំខែជំនួសវិញ ហើយប្រជុំប្រចាំខែនឹងត្រូវ បានកាត់បន្ថយ មិនសូវទៀងទាត់ដូចធម្មតាទេ។

សាក្សី បានបដិសេធស្គាល់ឈ្មោះសមាជិកគណៈមជ្ឈិមនៃបក្សកម្មុយនីស្តកម្ពុជា លើកលែង ប៉ុល ពត និង **នួន ជា**។ នៅក្នុងបទសម្ភាសន៍ជាមួយចៅក្រមស៊ើបអង្កេត លោក អ៊ុង រ៉ែន បានពន្យល់ថា បញ្ហាគោរពវិន័យ ត្រូវបានគេរាយការណ៍ទៅ ការិយាល័យ៨៧០ ចំណែកឯ បញ្ហាបច្ចេកទេស និង យុទ្ធវិធីត្រូវបានផ្ញើទៅមកជាមួយគណៈមជ្ឈិមដើម្បីធ្វើការសម្រេចចិត្ត។ ប៉ុន្តែ នៅចំពោះមុខតុលាការ សាក្សី បានសង្កត់ធ្ងន់ថា វាគ្រាន់តែជាការសន្និដ្ឋានផ្ទាល់របស់គាត់តែប៉ុណ្ណោះ។ លោក អ៊ុង រ៉ែន បានដឹងថា ស៊ូ សារឿន បានទៅភ្នំពេញជារៀងរាល់ខែ ឬពីរខែម្តង ប៉ុន្តែ គាត់ មិនបានប្រាប់ពីលទ្ធផលនៃការធ្វើដំណើរនេះគ្រប់ពេលនោះទេ លើកលែងតែពេលមានបញ្ហាបន្ទាន់ ដូចជាការឈ្លានពានរបស់ខ្មាំងសត្រូវ។ សាក្សី បានរ៉ាយរ៉ាប់ពីការអប់រំនយោបាយដោយ ស៊ូ សារឿន ពេលធ្វើទស្សនៈកិច្ចទៅ សៀមប៉ាង។ នៅទីនោះ គាត់ បានណែនាំប្រជាជនមិនឲធ្វើបាប ឬចោទសួរខ្មាំងនិងចំណាប់ខ្មាំងសំខាន់ៗទេ ប៉ុន្តែ *"បញ្ជូនឲមកកងពល ហើយកងពលបញ្ជូនទៅលើ។"*[18]

## ៤. កិច្ចការនៅសេនាធិការ

មានពេលមួយ លោក អ៊ុង រ៉ែន បានទទួលបញ្ជាពីមជ្ឈិមឲទៅ វឿនសៃ ខេត្តរតនគិរីដើម្បីជំនួស សាន ហៅ *០៦* អ្នកដែលបានផ្ទេរទៅខេត្តមណ្ឌលគិរី។ សាក្សី បានដឹងថា គាត់ ត្រូវបានគេចាត់តាំងឲនៅភ្នំពេញក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ ប្រហែលជា១ខែ ដើម្បីបានចូលតំណែងរបស់គាត់នៅ វឿនសៃ។ គាត់ បានអះអាងថា គាត់ ត្រូវបានអញ្ជើញឲមកប្រជុំរៀនសូត្រ ប៉ុន្តែដោយសារគាត់ធ្លាក់ខ្លួនឈឺ គាត់ បានស្នាក់នៅសេនាធិការ[19] ប៉ុន្តែ មិនទាន់អាចចូលរួមសកម្មភាពអ្វីបានទាំងអស់។ កិច្ចពិភាក្សាតទល់ពីចំនុចពេលវេលាដែលសាក្សីចាប់ផ្តើមការងារនៅសេនាធិការមានសភាពតានតឹង។ ក្នុងអំឡុងពេលសួរដេញដោលដោយព្រះរាជអាជ្ញាអន្តរជាតិ ឌេល លីសាក់ សាក្សី បានទទួចថា គាត់បានធ្វើការនៅទីនោះរយៈពេលខ្លីបំផុតក្នុង ឆ្នាំ ១៩៧៧ ទោះបីជាមានរបាយការណ៍របស់សេនាធិការមួយចំនួន ដែលមានឈ្មោះគាត់ក្នុងកាលបរិច្ឆេទចាប់ពី ឆ្នាំ ១៩៧៦ ក៏ដោយ។ ក្រោយមក សាក្សី បានបញ្ជាក់ថា គាត់បានសរសេររបាយការណ៍ដែលមានកាលបរិច្ឆេទ ២៤ ធ្នូ ១៩៧៦ ដែលមានផ្នែកខ្លះក្នុងរបាយការណ៍ បញ្ជាឲដកកម្មាភិបាលម្នាក់ ដែលគាត់ព្យាយាមអះអាងថា គាត់គ្រាន់តែសរសេររបាយការណ៍តែប៉ុណ្ណោះ មិនបានធ្វើសេចក្តីសម្រេចនោះទេ។[20] ប៉ុន្តែ គាត់ ក៏បាន

ទទួលស្គាល់ដែរថា គាត់ ត្រូវតែឃ្លាំមើលនិងសរសេររបាយការណ៍ទៅកាន់សេនាធិការពីកិច្ចប្រជុំ *"ជីវភាព"* ប៉ុន្តែ ទទូចថា គាត់ មិនអាចផ្តល់យោបល់ដើម្បីចាប់ខ្លួន ឬ បោសសម្អាតអ្នកណាចោលនោះទេ។

## ៥. ការបោសសម្អាតកម្មាភិបាល

លោក អ៊ុង វ៉ែន បានរ៉ាយរ៉ាប់ពីព្រឹត្តការណ៍មួយដែលបានកើតឡើង ពេលដែល ស៊ូ សារឿន បានបង្ហាញសារទូរលេខមួយ ចោទប្រកាន់ កែវ សារឿន ហៅ *ខៀវ* ជាអតីតប្រធានកងពល៨១ និង សមាជិកនៃគណៈកងពល ពីបទ *"ខូចសីលធម៌"* ជាមួយនារីម្នាក់ឈ្មោះ ហេង នារី។[21] សាក្សី បានពន្យល់ថា *"ក្នុងរបបនោះមិនសូវរវីរវល់នឹងបញ្ហានេះ (ស្រីញី) ប៉ុន្មានទេ។ តែមានរឿងគឺថា ច្បាស់ជាទៅហើយ។"*[22] កែវ សារឿន ត្រូវបានកោះហៅឲមកភ្នំពេញដើម្បីប្រជុំសិក្សាមួយ។ យោងតាម លោក អ៊ុង វ៉ែន- កែវ សារឿន បានចោទប្រកាន់គាត់ ពេលសារភាពក្នុងកិច្ចប្រជុំ។[23] ពេលសាក្សីបានត្រលប់មកភ្នំពេញវិញក្នុង ឆ្នាំ ១៩៧៧ ស៊ូ សារឿន បានប្រាប់គាត់ពីការចោទប្រកាន់នេះ ហើយបានបញ្ជូនគាត់ឲស្នាក់នៅ បឹងកន្សែង ក្នុងតួអន្លង់ដែលជាទីរួមខេត្តប្រចាំខេត្តរតនគិរី។ ក្រោយមក គាត់ ត្រូវបានចាត់តាំងឲទៅភ្នំពេញវិញ តាមរយៈសារទូរលេខមួយពី ការិយាល័យ ៨៧០ ដូច្នេះគាត់បានទៅព្រលានយន្តហោះ ដែលមានយន្តហោះមួយ កំពុងរងចាំគាត់នៅស្ទឹងត្រែង។ នៅតាមផ្លូវ ក្នុងស្រុក កូនមុំ ខេត្តរតនគិរី មានឡានមួយមកពីកងពល បានរាំងគាត់ ហើយប្រាប់គាត់ឲត្រលប់ទៅតួអន្លង់វិញ ដោយសារតែសភាពការណ៍មិនល្អនៅភ្នំពេញ។

បន្ទាប់មក ព្រះរាជអាជ្ញា លីសាក់ បានដាក់ឯកសារជាច្រើនសម្រាប់ចោទសួរសាក្សី ហើយឯកសារទាំងនេះត្រូវបានបញ្ជូនរវាង កងពល ៨០១ និង ការិយាល័យ ៨៧០ ដែលរៀបរាប់លម្អិតពីការចាប់ខ្លួននៅតាម *"មូលដ្ឋាន"* រួមទាំងទាហានវៀតណាម ដែលត្រូវបានចោទប្រកាន់ពីបទចារបុរស ប៉ុន្តែសាក្សីបានអះអាងថា គាត់មិនបានដឹងអំពីបញ្ហានេះទេ។ សាក្សី បាននិយាយថា គាត់មិនបានដឹង ថាតើវាជាគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យដើម្បីសួរចម្លើយខ្មាំងមុនពេលពួកគេត្រូវបាន*"កម្ទេច"* ពីព្រោះ នៅក្នុងកវរសេនាធំរបស់គាត់ កូនទាហានរបស់គាត់ បានស្នាក់នៅជាមួយគាត់ ហើយពួកគេមិនមានការវាយប្រហារជាមួយកងទ័ពវៀតណាមទេ។ លោក អ៊ុង វ៉ែន បានបញ្ជាក់ថា គាត់គ្រាន់តែបានដឹងពីមន្ទីរសន្តិសុខ អូរកន្សែង ពេលដែលគាត់ត្រូវបានចាត់តាំងឲទៅ បឹងកន្សែង ហើយប្រជាជននៅទីនោះ បានរអ៊ូរទាំពីការចាប់ខ្លួនកូនចៅរបស់ពួកគាត់ពីបទលួចដំឡូងដោយសារការស្រេកឃ្លាន។ ក្មេងៗទាំងនេះ ត្រូវបានដោះលែងភ្លាមៗ បន្ទាប់ពីមានការសំណូមពរទៅ ស៊ូ សារឿន ឲលើកលែងទោស។

## ៦. ឥរិយាបថ និង ភាពជឿជាក់របស់សាក្សី

សាក្សី ហាក់ដូចជាព្យាយាមជៀសវាងផ្តល់ចម្លើយជាក់លាក់លើលំដាប់កាលបរិច្ឆេទនៃអាជីពទាហានរបស់គាត់រហូតដល់ ឆ្នាំ ១៩៧៩។ ទោះបីជាមានសំណួរដដែលៗពីព្រះរាជអាជ្ញាក៏ដោយ គាត់នៅតែទទូចថា គាត់មិនបានមកដល់ការិយាល័យសេនាធិការ រហូតដល់ ខែកក្កដា ឆ្នាំ ១៩៧៦ ប៉ុន្តែចម្លើយរបស់គាត់ទៅកាន់សហចៅក្រមស៊ើបអង្កេត សក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ និង ព័ត៌មានដែលទទួលបានពីឯកសារនានា មិនមានភាពស៊ីសង្វាក់គ្នាលើបញ្ហានេះទេ។ លោក អ៊ុង វ៉ែន ក៏បានបដិសេធជាប់ពាក់ព័ន្ធនៅក្នុងសភាតំណាងប្រជាជន ទោះបីជាមានឈ្មោះរបស់គាត់ក្នុងបញ្ជីសមាជិកក៏ដោយ។[24] សាក្សី ក៏បាននិយាយ

ទទួចដែលថា គាត់មិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីស្នើឲចាប់ខ្លួន ឬបោសសម្អាតអ្នកណាម្នាក់ទេ។ វាបង្ហាញឲឃើញថា សាក្សី បានខ្លាចជាប់ពិរុទ្ធខ្លួនឯង រហូតដល់មានពេលមួយ ព្រះរាជអាជ្ញា លីសាក់ មានអារម្មណ៍ថាចាំបាច់ត្រូវតែធានាឲច្បាស់ជាមួយគាត់ថា គាត់មិនមែនជាជនដែលត្រូវបានចោទប្រកាន់ទេ។

## គ. សក្ខីកម្ម នោម សៃ

លោក នោម សៃ បានចាប់ផ្តើមសក្ខីកម្មរបស់គាត់នៅថ្ងៃចុងក្រោយនៃកិច្ចដំណើរការនីតិវិធីក្នុងសប្តាហ៍នេះ។[25] គាត់មានអាយុ ៦២ ឆ្នាំ ហើយសព្វថ្ងៃនេះ គាត់រស់នៅខេត្តឧត្តរមានជ័យ។ នៅទីនោះ គាត់ធ្វើការជាកសិករនិងបម្រើការជាប្រធានសមាគមអតីតយុទ្ធជនប្រចាំក្នុងស្រុកអន្លង់វែង។ សាក្សី បានផ្តល់សក្ខីកម្មពីបទពិសោធន៍របស់គាត់ ជាសមាជិកម្នាក់នៃទាហានខ្មែរក្រហម ការវាយលុកមកលើភ្នំពេញ ការបង្កើតកង៨០១ និង តួនាទីរបស់គាត់ជាប្រធានមន្ទីរសន្តិសុខ អូរកន្សែង។

### ១. ព្រឹត្តការណ៍នៅក្នុងភូមិភាគនិរតីមុនឆ្នាំ ១៩៧៥

សាក្សី នោម សៃ បានផ្តល់សក្ខីកម្មថា គាត់បានចូលរួមចលនាបដិវត្តន៍ តាមការកោះហៅរបស់ **សម្តេច នរោត្តម សីហនុ** នៅ ឆ្នាំ ១៩៧០ ដើម្បីប្រឆាំងនឹងរដ្ឋាភិបាល។ គាត់ បានចូលព្រៃនៅខេត្តកំពង់ស្ពឺ និង ខេត្តតាកែវ ដោយធ្វើការជាមួយខ្មែរក្រហមនិងកងកម្លាំងវៀតណាមខាងជើង។ ក្នុងឆ្នាំ១៩៧១ លោក នោម សៃ បានក្លាយជាមេក្រុមកងលេខ៦ ក្នុងអនុសេនាតូចទី១ នៃអនុសេនាធំទី១ នៃកងវរសេនាតូច ១៦០ ដែលស្ថិតនៅក្រោមការដឹកនាំរបស់ ស៊ូ សារឿន។ សាក្សី បានពន្យល់ថា មេរបស់ ស៊ូ សារឿន គឺ ឈិត ជឿន ហៅ *ម៉ុក* អ្នកដែលគ្រប់គ្រងភូមិភាគនិរតី។

លោក នោម សៃ បានពន្យល់ថា ភូមិភាគពិសេសត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ចលនាតស៊ូ និង ការពារភ្នំពេញ។ ភ្នំពេញត្រូវបានព័ទ្ធជុំវិញទាំងស្រុង ដោយកងពល៣ មានដូចជា កងពលលេខ១២ ប្រចាំប៉ែកខាងកើត កងពលលេខ១១ ប្រចាំប៉ែកខាងត្បូង និង កងពលលេខ១៤ ប្រចាំប៉ែកខាងពាយព្យ។ សាក្សី បានធ្វើការនៅក្នុងកងពលលេខ១១ ក្នុងឆ្នាំ ១៩៧៣ ក្រោមបញ្ជារបស់ ស៊ូ សារឿន អ្នកដែលបានប្រាប់គាត់ថា មេបញ្ជាការនៃភូមិភាគពិសេស គឺ វន វេត។ លោក នោម សៃ បាននិយាយថា នៅចុង ឆ្នាំ ១៩៧៣ ឬ ឆ្នាំ ១៩៧៤ ពាក់កណ្តាលនៃកងពលលេខ១១ រួមទាំងអនុសេនាតូចរបស់គាត់ ត្រូវបានបញ្ចូលជាមួយកងពលលេខ១៤ ដែលសាក្សីបានសង្កេតឃើញថា កងពលនេះ បានបាត់បង់កម្លាំងមួយចំនួនធំ។ មុនការវាយលុកចូលភ្នំពេញនៅ ឆ្នាំ ១៩៧៥ អង្គភាពរបស់សាក្សី ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលលេខ១៤ ហើយខ្លួនគាត់ផ្ទាល់ បានក្លាយជាមេបញ្ជាការរងនៃ អនុសេវាតូចមួយ។

ក្នុងរវាង ឆ្នាំ ១៩៧៣ និង ឆ្នាំ ១៩៧៤ អង្គភាពរបស់សាក្សី បានចូលរួមវាយប្រហារបីបួនដងដែរមកលើទាហាន លន់ ណុល នៅតំបន់ក្នុងខេត្តកំពង់ស្ពឺ។ គាត់ បានបន្តពន្យល់ថា ថ្នាក់លើបានសម្រេចពីវាសនារបស់ឈ្លើយសឹកទាហានរួចជាស្រេច ពីព្រោះ ពួកគេត្រូវបានបញ្ជូនទៅតំបន់មួយផ្សេងទៀតឆ្ងាយពីសមរភូមិជួរមុខ។ លោក នោម សៃ បានរ៉ាយរ៉ាប់ថា នៅពេល *"រំដោះ"* ឧត្តុង នៅខែមីនា ឆ្នាំ ១៩៧៤ កងទ័ពរបស់គាត់ បានឈរជើងនៅតាមផ្លូវលេខ៧៨ នៅ កំពង់ទួល ដូច្នេះហើយ បានជាគាត់មិនបានដឹងថា អ្នកណាជាអ្នកបានរៀបចំផែនការវាយប្រហារ ឬ វាសនារបស់ប្រជាជនក្រោយពេលភ្នំពេញ

ត្រូវបានវាយបែក។ សាក្សី បានឮពីការរំដោះនៅកន្លែងផ្សេងៗទៀត ដូចជា ខេត្តតាកែវ និង កំពង់ស្ពឺ ដែលក្រោយមកប្រជាជនត្រូវបានជម្លៀសចេញ ដោយបញ្ហាសន្តិសុខ និង មហិច្ឆតាចង់ក្តោមក្តាប់តំបន់ទាំងនេះ។ សាក្សី មិនបានដឹងពីកន្លែងដែលអ្នកជម្លៀសត្រូវបានគេបញ្ជូនទៅណានោះទេ។

នៅមុនការរំដោះភ្នំពេញក្នុង ឆ្នាំ ១៩៧៥ សាក្សី បានចូលរួមវគ្គសិក្សារៀនសូត្រ ដែលមានឯកសារសំខាន់ៗជាច្រើន ត្រូវបានចែកចាយឲ្យអ្នកចូលរួម។ ឯកសារទាំងនេះ បង្ហាញពីទិន្នន័យថ្មីៗបំផុតទាក់ទងនឹងការរីកចម្រើននៃចលនាតស៊ូបះបោរ យុទ្ធសាស្ត្រនិងផែនការវាយប្រហារម្តងម្កាល និង ការខិតខំប្រឹងប្រែងដើម្បីពង្រឹងសមត្ថភាពថ្នាក់ដឹកនាំសម្រាប់ការរំដោះប្រទេសជាតិជាចុងក្រោយ។ គាត់ បានអះអាងថា ទិសដៅផ្លូវការណ៍នាពេលនោះ គឺ *"រំដោះទឹក រំដោះដី រំដោះប្រទេស ឲ្យដំណើរយ៉ាងម៉េចឲ្យតែបានប្រជាជនរស់នៅឲ្យបានសេចក្តីសុខ។"*[26] តាមធម្មតា មេបញ្ជាការកងវរសេនាតូច ស៊ុ សារឿន បានធ្វើជាប្រធានបើកកិច្ចប្រជុំ។ លោក ឆោម សែ បានបន្តបកស្រាយថា *"ខ្មាំង"* ត្រូវបានកំណត់ថា ជាអ្នកដែលធ្វើការក្រោមរបប លន់ ណុល និងជាទាហាន លន់ ណុល។ គាត់ ក៏បានដឹងឮពី*"ជនក្បត់ទាំង៧"*នៃរបបនេះផងដែរ ប៉ុន្តែគាត់មិនអាចចាំបានថា គាត់បាន ដឹងព័ត៌មាននេះពីអ្នកណានោះទេ។

## ២. ការរំដោះនិងការជម្លៀសចេញពីភ្នំពេញ

លោក ឆោម សែ បានរៀបរាប់ថា មានការប្រយុទ្ធគ្នាតានតឹងអស់រយៈពេល៣ខែមុនពេល ភ្នំពេញត្រូវបានរំដោះ។ នៅថ្ងៃ ១៧ មេសា ១៩៧៥ អង្គភាពរបស់គាត់ បានវាយចូលពីតំបន់ពោធិ៍ចិនតុង ទៅក្រសួងឃោសនាការនៅកណ្តាលក្រុងភ្នំពេញ។ សាក្សី បានបញ្ជាក់ថា គាត់គ្រាន់តែដឹងថា ឈ្លើយសឹកទាហាននៃរបប លន់ ណុល ត្រូវបានគេបញ្ជូនទៅតាមស្រុកស្រែ។ លោក ឆោម សែ បានជឿជាក់ថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុង ត្រូវបានគិតទុកជាមុន ពីព្រោះ ការជម្លៀសប្រជាជនស្រដៀងៗគ្នានេះ បានកើតឡើងនៅតំបន់ផ្សេងៗទៀតពីមុនមក។ ពេលកងវរសេនាធំរបស់គាត់ ត្រូវបានណែនាំឲ្យជម្លៀសចេញពីទីក្រុង សាក្សីត្រូវបានប្រាប់ថា គោលបំណង គឺដើម្បីគ្រប់គ្រងស្ថានការណ៍ឲ្យបានប្រសើរ ដោយសារខ្មាំងនៅតែមាន *"ពាសវាលពាសកាល"*។ មិនមានការបែងចែកប្រជាជនតាមប្រភេទ ដែលត្រូវបានអនុញ្ញាតឲ្យស្នាក់នៅនោះទេ គឺថា អ្នកឈឺ ជនពិការ និងស្ត្រីមានផ្ទៃពោះទាំងអស់ក៏ត្រូវចាកចេញពីទីក្រុងដែរ។

ក្រោយពីការរំដោះទីក្រុងភ្នំពេញ កងពលរបស់ លោក ឆោម សែ ត្រូវបានបោះទីតាំងនៅខាងលិចផ្សារថ្មី។ គាត់ បានចូលរួមប្រជុំមួយធ្វើនៅស្តាតអូឡាំពិក ដែលពួកថ្នាក់ដឹកនាំខ្មែរក្រហមត្រូវបានប្រកាសជាផ្លូវការណ៍ ហើយពិធីរំឭកខួបនៃការបង្កើតយោធា ក៏ត្រូវបានប្រព្រឹត្តឡើងផងដែរ។ សមាជិកយោធានៃកងពល អនុសេនាតូច និង កងវរសេនាតូច ផ្សេងៗជាច្រើនបានចូលរួម ក្នុងខណៈដែលមេដឹកនាំ២១រូបនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានណែនាំជាសាធារណៈ ហើយសាក្សី បានឃើញជនជាប់ចោទទាំង៣ មានវត្តមាននៅទីនោះដែរ។ ការថ្លែងសុន្ទរៈកថាពីសំណាក់មេដឹកនាំទាំងនោះរួមទាំង លោក **នួន ជា** ត្រូវបានធ្វើឡើង។

## ៣. ការបង្កើតនិងការដាក់ពង្រាយរបស់កងពល៨០១

ក្រោយពីការរំដោះភ្នំពេញ លោក នោម សែ បានពន្យល់ថា កងពលទាំង៣របស់ភូមិភាគយោធាពិសេសត្រូវបានផ្តូរឈ្មោះនិងចាត់តាំងឡើងវិញ៖ កងពលលេខ១១ ក្លាយជាកងពល៦០៥ កងពលលេខ១២ ក្លាយជាកងពលលេខ៧០៣ និង កងពលលេខ១៤ផ្ទាល់របស់គាត់ ក្លាយជាកងពលលេខ៨០១។ ព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល បានដកសម្រង់ពីកិច្ចសម្ភាសន៍របស់សាក្សីជាមួយសហចៅក្រមស៊ើបអង្កេត ដែលគាត់បាននិយាយថា កងពលលេខ១៤ ត្រូវបានបង្កើតឡើងវិញជាកងពលលេខ៨០១ នៅក្នុងមហាសន្និបាតនៅស្តាតអូឡាំពិក ក្នុងខែកញ្ញា ឆ្នាំ ១៩៧៥។ គាត់ បានថ្លែងថា មានមនុស្សជាង១០០០នាក់ បានចូលរួមក្នុងមហាសន្និបាតនេះ។ ដោយមានការសួរដេញដោលជាបន្ត ថាតើគាត់សំដៅទៅលើមហាសន្និបាតនៅថ្ងៃ ២២ កក្កដា ១៩៧៥ ដែលមាននៅក្នុង*ទង់បដិវត្តន៍* ឬក៏យ៉ាងណា សាក្សី បានទទួលស្គាល់ថា គាត់មិនបានកត់ត្រាកាលបរិច្ឆេទទេ ប៉ុន្តែ ប្រធានបទនៅក្នុងមហាសន្និបាតចែងក្នុង*ទង់បដិវត្តន៍*នេះ មានសភាពស៊ីសង្វាក់គ្នានឹងមហាសន្និបាតដែលគាត់បានចូលរួម។

សាក្សី ត្រូវបានលើកតំណែងជាមេបញ្ជាការអនុសេនាតូច ដែលគ្រប់គ្រងទាហានជិត១០០នាក់ ហើយ គាត់ បានពន្យល់ថា មានកងវរសេនាធំ៣ និង កងវរសេនាតូច៣ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលលេខ៨០១។ តាមរយៈសាក្សី ការដាក់ពង្រាយកងពលនៅទិសឦសានប្រទេស មិនត្រូវបានប្រកាសឲសាធារណៈជនដឹងនោះទេ ប៉ុន្តែផ្តល់ដំណឹងតាមមេបញ្ជាការកងពល។ លោក នោម សែ បាននិយាយថា ស៊ូ សារឿន ហៅ *០៥* គ្រប់គ្រងកងពលលេខ៨០១ ហើយគាត់អះអាងថា ស៊ូ សារឿន មានអំណាចក្នុងការធ្វើសេចក្តីសម្រេច ដោយរៀបរាប់ការដឹកនាំរបស់គាត់ថាជា *"របបប្រធានមួយ"*។ សាក្សី បាននិយាយថា កងពលលេខ៨០១ មានទីតាំងជិតភូមិភាគឦសាន ហើយមានបំណង *"សហការគ្នា ជួយជាកម្លាំងផ្តល់សេវាកម្មគ្នា"* ប៉ុន្តែដោយសារគាត់មានឋានៈទាបពេក គាត់មិនអាចដឹងពីការរៀបចំ បែងចែកការងាររវាងក្រុមទាំងពីរនេះទេ។

## ៤. ការបោសសម្អាតក្នុងកងពលលេខ៨០១ និង មន្ទីរសន្តិសុខអូរកន្សែង

លោក នោម សែ មិនបានដឹងពីមូលហេតុនៃការបង្កើតមន្ទីរសន្តិសុខអូរកន្សែងនៅក្នុងកងពលលេខ៨០១ នៅចុងឆ្នាំ១៩៧៦ ប៉ុន្តែ គាត់ បានប្រាប់ថា នៅពេលនោះ មានជនសេរីនៅក្នុងជួរកងទ័ពជាច្រើន *"ខ្វះសណ្តាប់ ធ្នាប់"* និងតម្រូវឲមានការគ្រប់គ្រង។ ព្រះរាជអាជ្ញា វ៉ាយដ៍ ដេស្មាឯល បានចោទសួរគាត់យោងតាមចម្លើយរបស់គាត់ទៅកាន់សហចៅក្រមស៊ើបអង្កេត ដែលគាត់និយាយថា មន្ទីរអូរកន្សែង ត្រូវបានបើកដំណើរការពេល *"ដែល មានចលនាខ្មាំងផ្ទៃក្នុងកើតឡើងទូទាំងប្រទេស។"*[27] សាក្សី បានបកស្រាយថា អ្នកដែលមានឋានៈជា វរៈសេនីយឯក និង អ្នកដែលមានឋានៈខ្ពស់ផ្សេងទៀតត្រូវបានដកចោល ដូច្នេះ បញ្ហាសន្តិសុខ បានក្លាយជាបញ្ហាចំបង។

យោងតាមសាក្សី អ្នកបម្រើត្រូវបានចាប់ខ្លួននិងបញ្ជូនទៅកាន់មន្ទីរអូរកន្សែង តាមការសម្រេចរបស់ប្រធានកងពល។ លោក នោម សែ បានអះអាងថា ទាហានដែលត្រូវបានបញ្ជូនទៅ មានឋានៈទាបជាងតំណែងផ្ទាល់របស់គាត់ជាអនុសេនីយ៍ទោឬអនុសេនីយ៍ត្រី។ គាត់ បានសន្មតថា ទាហានដែលមានតំណែងខ្ពស់ជាង ត្រូវបានបញ្ជូនទៅភ្នំពេញនិងក្រោយមកត្រូវបានចាប់ខ្លួន ពីព្រោះ គេកត់សម្គាល់ថា មន្ត្រីយោធា

ទាំងនេះ បានបាត់ខ្លួនក្រោយពីពួកគេបានទៅភ្នំពេញ។ លោក ឆោម សែ បានដឹងថា វាមិនមែនជារឿងចម្លែកអ្វីនោះទេ សម្រាប់កម្មាភិបាលថ្នាក់លើទទួលការកោះហៅឲទៅភ្នំពេញ ហើយបន្ទាប់មកក៏បាត់ខ្លួន ដូចជាករណី តា យ៉ា ដែលជាប្រធានភូមិភាគឦសាន។

ព្រះរាជអាជ្ញាអន្តរជាតិ បានប្រឈមសាក្សីនឹងឯកសារមួយពីបុគ្គល រឿន ដែលជាលេខាភូមិភាគកងពលលេខ៨០១ បានដាក់ជូន អ៊ំ ៨៩ ដែលបានណែនាំការអនុវត្តន៍នៃវិធានការចំនួន៥ ពាក់ព័ន្ធនឹងការចាប់ខ្លួនខ្មាំង ក្លែងជាកម្មាភិបាល ក៏ដូចជាអ្នកដែលបរាជ័យសម្របសម្រួលខ្លួនឯងក្រោយ ពីទទួលបានការអប់រំកែប្រែឡើងវិញ។[28] សាក្សី បាននិយាយបញ្ជាក់ថា ទោះបីជាវិធានការទាំងនេះត្រូវបានអនុវត្តនៅក្នុងអង្គភាពផ្សេងៗក៏ដោយ វាមិនត្រូវបានយកមកប្រើប្រាស់នៅក្នុងអង្គភាពរបស់គាត់ទេ។ លោក ឆោម សែ បានអះអាងថា ក្រោយពី គាត់ បានក្លាយជាប្រធានមន្ទីរអូរកន្សែង គាត់ មិនបានយល់ពីដំណើរការក្នុងការចាប់ខ្លួនមនុស្ស ដែលបានបញ្ជូនមកគាត់ទេ។ ប៉ុន្តែ នៅក្នុងសំណួរក្រោយៗទៀត ព្រះរាជអាជ្ញា វ៉ាយដ៏ ដេស្មាឯល បានដកស្រង់ផ្នែកមួយពីកិច្ចសម្ភាសន៍របស់គាត់ជាមួយសហចៅក្រមស៊ើបអង្កេត ដែល សាក្សី បានពន្យល់ថា ប្រជាជន បានក្លាយជាអ្នកទោសឃោឌា ដោយសារតែការសារភាពរបស់ពួកគេផ្ទាល់ ពីព្រោះពួកគេបានទទួលការកោះហៅពីមន្ទីរអូរកន្សែង ឬ ពួកគេត្រូវបានគេចោទដាក់នៅក្នុងចម្លើយសារភាពនៅភ្នំពេញ។ លោក ឆោម សែ បាននិយាយថា ចម្លើយសារភាពទាំងនេះ ត្រូវបានបញ្ជូនទៅកាន់ ស៊ូ សារឿន ប្រហែលជាតាមរយៈវិទ្យុ និង ជាបន្តបន្ទាប់មក គាត់ បានផ្ញើបន្តបញ្ជីឈ្មោះអ្នកដែលត្រូវបានចោទដាក់ឬឆ្លើយចោទប្រកាន់ដាក់។ សាក្សី បានធានាថា អ្នកសារភាពទាំងអស់នេះ គឺជាទាហានកងពលលេខ៨០១ ដែលត្រូវបានដកចេញ ទោះបីជាគាត់មិនអាចចាំឈ្មោះអ្នកទាំងអស់នោះក៏ដោយ។ គាត់ក៏បាននិយាយដែរថា ការណែនាំតែមួយគត់ ដែលគាត់ទទួលបានពី ស៊ូ សារឿន គឺត្រូវតែរក្សាការប្រុងប្រយ័ត្ននិងយកចិត្តទុកដាក់ ហើយ ប្រសិនបើ បញ្ហានេះមានលក្ខណៈធ្ងន់ធ្ងរស៊ីជម្រៅ ឬជាប្រព័ន្ធបណ្តាញ គាត់នឹង *"មានវិធានការទៅដល់អង្គភាព។"*

លោក ឆោម សែ បានពន្យល់ថា ចម្លើយសារភាពពីអ្នកជាប់ឃុំឃាំងអូរកន្សែង ត្រូវបានផ្ញើទៅ ស៊ូ សារឿន ទោះបីជាគាត់មិនអាចចាំបាន ថាតើរបាយការណ៍ទាំងនេះ ត្រូវបានបញ្ជូនបន្តទៅកាន់មេបញ្ជាការរបស់គាត់ញឹកញាប់ដល់កម្រិតណានោះទេ ប៉ុន្តែ ភាពញឹកញាប់អាចកើនឡើងអាស្រ័យលើភាពអាសន្ននៃស្ថានការណ៍។ ពេលដែលត្រូវបានសួរពីគោលបំណងនៃរបាយការណ៍ទាំងនេះ សាក្សី បាននិយាយថា របាយការណ៍ទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីកំណត់ ថាតើវាជាបញ្ហានយោបាយ បញ្ហាប្រព័ន្ធបណ្តាញខ្មាំង ឬ គ្រាន់តែជាបញ្ហាជាន់ដានតាមគេ។ របាយការណ៍ទាំងនេះ ក៏ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់មេបញ្ជាការក្នុងការវិនិច្ឆ័យ ថាតើបុគ្គលម្នាក់គួរត្រូវចាប់ខ្លួន ឬក៏ត្រូវដាក់វិន័យ។

